## វដ្តរៀនសូត្រពីសកម្មភាព (កែសំរួលអោយមានលក្ខណៈងាយយល់)

ដោយ ឡេងឆាយ

វដ្តរៀនសូត្រពីសកម្មភាពជាដំណើរការរៀនសូត្រប្រកបដោយស្មារតីភ្ញាក់រលឹក ចេញពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ និងពីបទពិសោធន៍របស់អ្នកដទៃ ដើម្បីលើកកំពស់ការអនុវត្តនាពេលអនាគត (ទាំងជីវិតផ្ទាល់ខ្លួន និងការងារអាជីព)។

### សកម្មភាព

រំលឹកនូវអ្វីដែលបានកើតឡើងជាក់ស្តែង (ទាំងរំពឹងទុក និងមិនបានរំពឹងទុក) រួមទាំងអារម្មណ៍អ្នកពាក់ព័ន្ធនឹងបទពិសោធន៍នោះ

### ផែនការ

ផ្អែកលើមេរៀនដែលទទួលបាន អ្នកអាចកំនត់ថាត្រូវធ្វើអ្វីអោយខុសពីនោះនាពេលអនាគត ប្រសិនបើអ្នកជួបប្រទះស្ថានភាពប្រហាក់ប្រហែលនេះទៀត។




### ការឆ្លុះបញ្ចាំង

ចំពោះសកម្មភាពនីមួយៗ៖

១. គិតពីអ្វីដែលដំណើរការបានល្អ ហើយ វិភាគរកកត្តាជួយគាំទ្រ។

២. គិតពីអ្វីដែលធ្វើមិនបានល្អ ហើយស្វែងរកកត្តាដែលរារាំង។

### ការរៀនសូត្រ

ទាញចេញនូវមេរៀនទទួលបានពីការឆ្លុះបញ្ចាំង។ វាអាចជាមេរៀនបែបវិជ្ជមាន ឬអវិជ្ជមាន។ វាជាការសន្និដ្ឋាននានា ការយល់ឃើញថ្មីៗ ឬ អ្វីដែលអ្នករកឃើញថ្មីៗ។



វដ្តរៀនសូត្រពីសកម្មភាពដែលល្អគឺជារ៉ឺស័ររៀនសូត្រទៅមុខ ដែលនាំទៅរកប្រសិទ្ធភាពកាន់តែខ្លាំងឡើងៗ។ ឥទ្ធិពលរៀនសូត្រអាចសំរេចបានពេញលេញ លុះត្រាតែវដ្តរៀនសូត្រមួយ បានពង្រឹងបន្ថែម ទៅលើវដ្តរៀនសូត្រមុនៗ ដើម្បីលើកកំពស់ប្រសិទ្ធភាពនៃសកម្មភាពអនាគត។

**ចុះអ្នកវិញ ធ្លាប់ប្រើវដ្តរៀនសូត្រពីសកម្មភាពនេះទេ?**


This learning article shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.